កាលបរិច្ឆេទ :៉

មាតាបិតា ឬអាណាព្យាបាលជាទីរាប់អាន :

សាលារៀនយើងខ្ញុំ ត្រូវបានជ្រើសរើសឱ្យចូលរួមក្នុងការវាយតម្លៃការរីកចម្រើនវិស័យសិក្សាធិការថ្នាក់ជាតិ ណាត្យិនាល ៅសសសេសមនេត្យថ ដ៉ុចាត្យិនាល ភវ្យៃងរសេស ១ណៅភែចដែលត្រូវបានទទួលស្គាល់ផងដែរថាជា ប័ណ្ណរបាយការណ៍ថ្នាក់ជាតិ ។ ណៅភែ ត្រូវបានផ្តល់ជូនដល់ សិស្សរៀនថ្នាក់ទី ៤ និង ទី ៨ នៅក្នុងរដ្ឋចំនួន ៥០ រួមទាំងឱ្យស្រ្តីកកូឡុំប៊ីផងដែរ ។ ឆ្នាំនេះ ណៅភែ នឹងរៀបចំការវាយតម្លៃចំនួនបីនៅក្នុងរដ្ឋរបស់ យើង និងទូទាំងប្រទេសគឺ អំណាន គណិតសាស្ត្រ និង វិទ្យាសាស្ត្រ ។ កុមារម្នាក់ៗដែលត្រូវបានជ្រើសរើស នឹងត្រូវប្រឡងមុខវិជ្ជាតែ**មួយ**គត់ ក្នុងចំណោមមុខវិជ្ជាទាំងនេះ ។

ការវាយតម្លៃនៃ ណៅភែ នឹងប្រព្រឹត្តិឡើងនៅថ្ងៃទី ហើយនឹងប្រើពេលប្រហែល ១ ម៉ោង ដើម្បី ត្រួតពិនិត្យកិច្ចការ ។ គំរូនៃសិស្សក្នុងថ្នាក់របស់យើងខ្ញុំ នឹងត្រូវបានជ្រើសរើសដើម្បីទទួលបានការវាយតម្លៃទៅលើ អំណាន គណិតសាស្ត្រ ឬវិទ្យាសាស្ត្រ ហើយកូនរបស់លោក-អ្នកប្រហែលអាចជាផ្នែកមួយនៃគំរូនោះ ។ *ចម្លើយតបទាំងអស់ ត្រូវបានរក្សា ការសម្ងាត់ ហើយគ្មានលទ្ធផលណាមួយ នឹងត្រូវបានរាយការណ៍ជូន ឬអំពីសាមីសិស្ស ឬសាមីសាលារៀនឡើយ* ។នេះមានន័យថា ឈ្មោះសិស្ស ដែលចូលរួមក្នុង ណៅភែ មិនត្រូវបានកត់ត្រាទុកនៅលើសម្ភារៈវាយតម្លៃណាមួយ ដែលត្រូវបានយកចេញពីសាលាទេ ហើយកម្រិត ឬការរីកចម្រើនរបស់កូនរបស់លោក-អ្នកនៅក្នុងសាលារៀន នឹងមិនទទួលរងឥទ្ធិពលពីការចូលរួមទេ ។

ទិន្នន័យ និងលទ្ធផលរបស់ ណៅភែ ត្រូវបានប្រើប្រាស់នៅក្នុងរដ្ឋរ៉ូដអាយស៍ឡេន ដើម្បីធ្វើសេចក្តីសម្រេចពាក់ព័ន្ធនឹងការអប់រំ ។ ដើម្បីជួយនាំផ្លូវដល់ការធ្វើសេចក្តីសម្រេចទាំងនេះ ណៅភែ សួរទៅកាន់សិស្សនូវសំណួរអំពីបទពិសោធន៍នៅសាលារៀន សាវតាររបស់ពួកគេ ហើយនិងសួរអំពីអ្វីដែលគ្រូបានបង្រៀននៅក្នុងថ្នាក់ បន្ថែមលើសំណួរពាក់ព័ន្ធនឹងបញ្ហាមុខវិជ្ជា ។ សំណួរទាំងនេះមិនសួរអំពីជំនឿ ឬអាកប្បកិរិយាផ្ទាល់ខ្លួនទេ។ សិស្សអាចលុបសំណួរ ឬផ្នែកណាមួយនៃការវាយតម្លៃ ដែលពួកគេមិនចង់ឆ្លើយបាន ។ ប្រសិនបើលោក-អ្នកមិនចង់ឱ្យកូនលោក-អ្នក ចូលរួមនៅក្នុងការវាយតម្លៃនេះទេ សូមទាក់ទងមកកាន់៉ តាមរយៈ៉ ។ **ចម្លើយតបទាំងអស់ ត្រូវតែបានសរសេរជាលាយលក្ខណ៍អក្សរ និងត្រូវបានទទួលបានដោយសាលារៀនមិនហួស** ______៉ ។

យើងខ្ញុំពេញចិត្តចំពោះការចូលរួមរបស់កុមារម្នាក់ៗដែលត្រូវបានជ្រើសរើស ។ សិស្សដែលចូលរួមក្នុង ណៅភែ នឹងដើរតួនាទីដ៏សំខាន់មួយ ក្នុងការគូររូបភាពអ្វីដែលសិស្សសាលានៅក្នុងរដ្ឋ និងប្រទេសរបស់ពួកយើងកំពុងតែសិក្សា ។

សម្រាប់ព័ត៌មានបន្ថែមអំពី ណៅភែ និងសម្រាប់លទ្ធផលនៃ ណៅភែ លោក-អ្នកអាចចូលទស្សនាគេហទំព័រ របស់ក្រសួងសិក្សាធិការនៃរដ្ឋរ៉ូដអាយស៍ឡេន ១ហាតតផ៉ី.៉ ោិដេ ោិ ៉ៃៀវ.ៅសសសេសមនេត.នាផេ ៉ាសផខច ឬគេហទំព័រនៃប័ណ្ណរបាយការណ៍ថ្នាក់ជាតិតាម ហាតតផ៉..នចសេ ៉ាដេ ៉ៃៀវ.នាត្យិនសរផៀវតចារដ ។ ប្រសិនបើលោក-អ្នកមានចម្ងល់ សូមទាក់ទងមក ៖ពតហារេ ិនេកេ ៅងនី តាមរយៈទូរស័ព្ទលេខ ២២២-៨៤៩៣ ឬតាមរយៈ ៖ពតហារេ ៉ាងនី ៖ៃិដេ ោិ ៉ៃៀវ ។
កូនសៀវភៅណែនាំមួយ និងឧទាហរណ៍ជាច្រើននៃ សំណួរប្រឡង
ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងសំណួរដែលនឹងត្រូវបានសួរនៅលើការវាយតម្លៃឆ្នាំនេះ មាននៅលើគេហទំព័រទាំងពីរ និងនៅការិយាល័យសាលារៀន ប្រសិនបើលោក-អ្នកចង់ឃើញថាតើការប្រឡងមើលទៅយ៉ាងណានោះ ។ ប្រសិនបើលោក-អ្នកមានចម្ងល់ ឬកង្វល់ សូមទាក់ទងមកកាន់ ។

ដោយក្តីរាប់អានដ៏ស្មោះស្ម័គ្រ ។

នាយកសាលា១ឈ្មោះសាលារៀនច